ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៦៦ ស្តីពីការប្រោសព្រះរាជទាន នូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម.លោកជំទាវ និង អស់លោក ចំនួន ១៩ រូប ៨១៥០

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៦៧ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១-Miss. PANADDA PETCHLUAN,Professor,Ubon Rajathanee University.

២-Assistant Professor.Dr.MANOON SRIVIRAT,Vice President for Planning and Information System, Ubon Rajathanee University. ៨១៥២

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៦៨ ស្តីពីការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ **សួស អង្គារ៉** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៨១៥៣

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៦៩ ស្តីពីការតម្លើងឋានៈជូនឯកឧត្តម នាយក.នាយករង ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចំនួន ០៣ រូប ៨១៥៤

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៧០ ស្តីពីការតែងតាំងឯកឧត្តម **ហ៊ីង ប៊ុនហៀង** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៨១៥៥

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៧១ ស្តីពីការតែងតាំងឯកឧត្តម **ហ៊ុយ ពិសិដ្ឋ** ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៨១៥៦

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៧២ ស្តីពីការតម្លើងឋានៈជូនឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៨១៥៧

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៧៣ ស្តីពីការតម្លើងឋានៈជូនឯកឧត្តម
យូ ស៊ុនឡុង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៨១៥៨

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៧៤ ស្តីពីការតម្លើងឋានៈជូនឯកឧត្តម
ទ្រឹម យិនឡៀង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៨១៥៩

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៧៣ ស្តីពីការតម្លើងឋានៈជូនឯកឧត្តម
ប្រាក់ សុខុន ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៨១៦០

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៧៣ ស្តីពីការតម្លើងឋានៈជូនឯកឧត្តម
មល់ រឿម ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៨១៦១

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៧៧ ស្តីពីការតម្លើងឋានៈជូនឯកឧត្តម
ស្រ៊ី ថាមរុង្គ ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
មានឋានៈស្មើ រដ្ឋមន្ត្រី ៨១៦២

២៧-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤៧៨ ស្តីពីការតម្លើងឋានៈជូនឯកឧត្តម
ម៉ម សារិន ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
មានឋានៈស្មើ រដ្ឋមន្ត្រី ៨១៦៣

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

០២-១០-២០០៧ -អនុក្រឹត្យលេខ ១៤២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨១៦៤

០៣-១០-២០០៧ -អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានចារកម្ម នៃក្រសួងមហាផ្ទៃ ៨១៦៦

០៣-១០-២០០៧ -អនុក្រឹត្យលេខ ១៤៤ អនក្រ.បក ស្តីពីការបំពេញបន្ថែម ឯកសណ្ឋាន របស់នាយកដ្ឋាន
កម្ពុជា ត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" ៨១៦៨

២៨-៩-២០០៧ -អនុក្រឹត្យលេខ ៧៩៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨១៧២

០២-១០-២០០៧ -អនុក្រឹត្យលេខ ៨០០ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ៨១៧៣

០២-១០-២០០៧ -អនុក្រឹត្យលេខ ៨០១ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែង ជូននាយនគរបាលជាតិ ជាន់ខ្ពស់ ៨១៧៤
០២-១០-២០០៧ -អនុក្រឹត្យលេខ ៨០២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨១៧៦
០២-១០-២០០៧ -អនុក្រឹត្យលេខ ៨០៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨១៧៨
០២-១០-២០០៧ -អនុក្រឹត្យលេខ ៨០៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៨១៨១
០២-១០-២០០៧ -អនុក្រឹត្យលេខ ៨០៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨១៨២
០២-១០-២០០៧ -អនុក្រឹត្យលេខ ៨០៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨១៨៣
០២-១០-២០០៧ -អនុក្រឹត្យលេខ ៨០៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨១៨៤
០២-១០-២០០៧ -អនុក្រឹត្យលេខ ៨០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨១៨៥
០៣-១០-២០០៧ -អនុក្រឹត្យលេខ ៨០៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ៨១៨៦
០៣-១០-២០០៧ -អនុក្រឹត្យលេខ ៨១០ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨១៨៧

III-ការិយាល័យក្រសួង

១-ទីស្តីការក្រសួងមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១២-៦-២០០៧ -ប្រកាសលេខ ៤៦៥ សហវ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ ២០០៧
(ត មកពីរាជកិច្ច លេខ ៤៩...ដល់...៧៤) ៨១៨៥

២-ទីស្តីការក្រសួងមន្ត្រីក្រសួងពាណិជ្ជកម្ម

១២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០១៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ីន វឌ្ឍសាធី គ្រុប ខូ អិលធីឌី** ៨២៣៣
១២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **បញ្ញា ម៉ូ ស្តារ ខូ អិលធីឌី** ៨២៣៥
១២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០២១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អូសិន តើរីដាយ** ៨២៣៧

២៥

១២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស.ខឡូនា ភនចាខ** ៨២៣៩

១២-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេម ហ្វាម៉ា** ៨២៤១

១៣-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០២៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិន.ធី.តី. អឹមផត អិចផត** ៨២៤៣

១៣-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាន់សាញ-ឌប អ៊ិនធើណេសិនណល ឌីវេឡុបមេន** ៨២៤៥

១៣-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេនជ័ ក្រេប (ខេមបូឌា) អិលធីឌី** ៨២៤៧

១៣-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៣២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ក្រេប ហៅស៍ (ខេមបូឌា) អិលធីឌី** ៨២៤៨

១៣-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យ៉ឺង គីម អាន ខូអបពើរេសិន** ៨២៤៩

១៣-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៤២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុខ ណារី** ៨២៥១

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្តម គិត ឆាង
២-ឯកឧត្តម ទិញ ហ៊ួរ
៣-ឯកឧត្តម ហុង ពីទ
៤-ឯកឧត្តម ឡុច សារ៉េត
៥-ឯកឧត្តម ថៃ ធីណូ
៦-ឯកឧត្តម ផាត់ ប៊ុន
៧-ឯកឧត្តម ស ថេង
៨-ឯកឧត្តម វស់ ទណ្ណា
៩-លោក ជួន ទិបុល

- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១-ឯកឧត្តម ឯក ស៊ុនចាន់
២-ឯកឧត្តម ម៉ា ស៊ុនហ៊ួត
៣-ឯកឧត្តម ទ៉ា ឈុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១-ឯកឧត្តម ឈុន អួន

២-ឯកឧត្តម ប្រាក់ ចំរើន

៣-ឯកឧត្តម គុក គឹមសាយ

៤-លោកជំទាវ ឆោម សោភ័ណ្ឌី

- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

១-ឯកឧត្តម គុង សេង

២-ឯកឧត្តម លឹម ឆខាយ

៣-ឯកឧត្តម ជា ចាចរះជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៩.៤៩០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ: ៤៦៤ ច.ល

ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ១០ ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ជិនកេន

នស/រកត/០៩០៧/៤៦៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

ចំពោះ

១-Miss. PANADDA PETCHLUAN, Professor,
Ubon Rajathanee University.

២-Assistant Professor.Dr. MANOON SRIVIRAT,
Vice President for Planning and Information System,
Ubon Rajathanee University.

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៩.៤៩១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ: ៤៥ ច.ល
ជើងប្រមូលចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤៦៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ សូស អង្គារ៍ ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧រល.០៧០៩.៤៩២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ: ៤៤៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤៦៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានៈជូន :

១- ឯកឧត្ដម ហូ សិទ្ធី នាយកខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី

២- ឯកឧត្ដម ប្រាក់ វណ្ណឌី នាយករងខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី

៣- ឯកឧត្ដម ង៉ែត បូរី នាយករងខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

ពរល.០៧០៩.៤៩៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ: ៤៤៨ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧
[illegible]រាជរដ្ឋាភិបាល
[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ហ៊ីង ប៊ុនហៀង ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៩.៤៩៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខៈ ៤៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៨៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ហ៊ុយ ពិសិដ្ឋ ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤៧.០៧០៩.៤៩៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ: ៤៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០០៧
[illegible] រាជរដ្ឋាភិបាល

យុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤៧២

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានៈជូនឯកឧត្ដម អួន ព័ន្ធមុនីរ័ត្ន ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

ពរល.០៧០៩.៤៩៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ ៤៩១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានៈជូនឯកឧត្តម យូ ស៊ុនឡុង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧ល.០៧០៩.៤៩៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ: ៤៥៣ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៨៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានៈជូនឯកឧត្តម ឌិម យ៉ិនទៀង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

៣រល.០៧០៩.៨៩៨

លេខៈ ៨៥៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

យូន ជីនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤៧៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានៈជូនឯកឧត្ដម ប្រាក់ សុខុន ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣រល.០៧០៩.៤៩៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ: ៤៥៥ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានៈជូនឯកឧត្តម មល់ រឿប ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤ល.០៧០៩.៥០០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ: ៤៥៦ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤៧៧

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានៈជូនឯកឧត្ដម ស៊្រី ថាមរុង្គ ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

ពរល.០៧០៩.៥០១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ:៤៥៧ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០០៧
ទីស្ដីការគណៈរដ្ឋមន្ត្រី

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤៧៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានៈជូនឯកឧត្តម ម៉ម សារិន ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៩.៥០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ ៤៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ២.១១៥.២៦១.២០០ រៀល (ពីរពាន់មួយរយដប់ប្រាំលានពីររយហុកសិបមួយពាន់ពីររយរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ (ការទិញ) ជូនទីស្ដីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទូទាត់សងថ្លៃប្រើប្រាស់ថាមពលអគ្គិសនី ដែលបានជំពាក់ពីឆ្នាំ ២០០៣-២០០៥ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី០៤ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្ដីគោរពជូន

សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៣ . អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតនាយកដ្ឋានចារកម្ម នៃក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ .-

ត្រូវបានបង្កើតនាយកដ្ឋានចារកម្ម ចំណុះនាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សំរាប់បំពេញភារកិច្ចប្រមូលពត៌មានក្រៅប្រទេស សំដៅបំរើអោយការងារការពារសន្តិសុខជាតិ ។

មាត្រា២ .-

នាយកដ្ឋានចារកម្មមានភារកិច្ច ដូចខាងក្រោម :

- ផ្តើមស្នើចាត់តាំង មន្ត្រីប្រតិបត្តិការនៅអមស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ដោយមិនបំពេញការងារជាអគ្គកុងស៊ុល ឬផ្តើមស្នើចាត់តាំង មន្ត្រីជាតំណាងអង្គការ សមាគមផ្សេងៗ ដើម្បីបំពេញការងារចារកម្មក្រៅប្រទេស ។
- ប្រមូលពត៌មានពាក់ព័ន្ធដល់ការប៉ះពាល់អធិបតេយ្យភាព សន្តិសុខ សេដ្ឋកិច្ច នយោបាយ សន្តិសុខសង្គម របស់ព្រះរាជាណាចក្រកម្ពុជា និងផ្តើមស្នើរាល់គោលការណ៍ និងវិធានការផ្សេងៗជូនថ្នាក់ដឹកនាំពិនិត្យសំរេច ។
- សហការការពារសុវត្ថិភាពជូនពលរដ្ឋកម្ពុជាមាន និស្សិត កម្មករ ពលករ ពាណិជ្ជករ ទេសចរណ៍ គណប្រតិភូ និងមន្ត្រីទូតកម្ពុជា ដែលធ្វើដំណើរ ស្នាក់នៅ បំពេញភារកិច្ចនៅក្រៅប្រទេស តាមរយៈនេះចលនាគេចូលរួមចំណែកការពារសន្តិសុខជាតិ ។
- ក្តាប់បានអំពីផែនការសង្គ្រាមចិត្តសាស្ត្រនានានៅក្រៅប្រទេស ដែលជះឥទ្ធិពលដល់នយោបាយ សេដ្ឋកិច្ចសង្គម និងសន្តិសុខជាតិ ។

- ជាជំហានៗ ផ្តើមស្នើពង្រីកការងារចារកម្មបច្ចេកវិទ្យា បំរើការងារការពារប្រទេស ការពារសន្តិសុខជាតិ និងអន្តរជាតិ ។
- សហការជាមួយបណ្តាស្ថាប័នចារកម្មបរទេសនានា ដើម្បីផ្លាស់ប្តូរពត៌មាន ឬសហប្រតិបត្តិការ ទប់ស្កាត់អំពើភេរវកម្មអន្តរជាតិ និងបទល្មើសនានាដែលប៉ះពាល់ដល់ខឿនសន្តិសុខជាតិ ដោយឈរលើផលប្រយោជន៍ ស្របច្បាប់នៃប្រទេសនីមួយៗ ។
- សហការជាមួយអង្គភាពជំនាញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ និងបណ្តាក្រសួង ស្ថាប័ន ដើម្បីចាត់បញ្ចូលមន្ត្រីទៅក្នុងក្រសួង ស្ថាប័នទាំងនោះសំដៅបំពេញការងារចារកម្មក្រៅប្រទេស ។
- សហការជិតស្និទ្ធជាមួយសមត្ថកិច្ចជំនាញនានារបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីស៊ើបបញ្ជាក់រកអោយឃើញមុខសញ្ញាចារកម្មដែលបំរើអោយបរទេស ។
- គ្រប់ពត៌មានចារកម្មប្រមូលបានត្រូវវិភាគ វិនិច្ឆ័យ អោយបានគ្រប់ជ្រុងជ្រោយ រួចរាយការណ៍ជូនថ្នាក់ដឹកនាំពិនិត្យសំរេច ។
- លើកគំរោងសំភារៈ ឧបករណ៍បច្ចេកទេស បំរើកិច្ចប្រតិបត្តិការចារកម្ម ដាក់ស្នើជូនថ្នាក់ដឹកនាំពិនិត្យសំរេច ។
- ធ្វើផែនការបណ្តុះបណ្តាលរយៈពេលខ្លី វែង ដើម្បីកសាងធនធានមនុស្ស ទាំងជំនាញ ទាំងភាសាបរទេស និងបច្ចេកទេសវិទ្យាសាស្ត្រទូទៅដល់មន្ត្រីក្រោមឱវាទ ។
- ធ្វើការងាររដ្ឋបាល បុគ្គលិក គណនេយ្យ ភស្តុភាររបស់នាយកដ្ឋាន តាមការកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់អោយ ។

មាត្រា៣ ..

នាយកដ្ឋានចារកម្ម ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយ ។

មាត្រា៤ ..

នាយកដ្ឋានចារកម្មមានការិយាល័យមួយចំនួនចំណុះ ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានចារកម្ម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

មាត្រា៥ ..

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា៦ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ១០ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបំពេញបន្ថែម ឯកសណ្ឋាន របស់នាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

(ខក)

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល"
- តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១ :

បំពេញបន្ថែម ខ្លឹមសារមួយចំនួនលើអនុក្រឹត្យលេខៈ ១៨៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់ របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" សំរាប់មន្ត្រីរាជការ ប្រើប្រាស់ក្នុងពេលប្រតិបត្តិការ នៅមន្ទីរពិសោធន៍, នៅទីផ្សារ, នៅតាមព្រំដែន និងប្រើប្រាស់សំរាប់ពិធីការ ។

មាត្រា ២ :

ខ្លឹមសារដែលត្រូវបំពេញបន្ថែម ត្រូវបានកំណត់ដូចតទៅ ÷

១- ឯកសណ្ឋាន :

- អាវសំរាប់ប្រើប្រាស់នៅ មន្ទីរពិសោធន៍

ប្រភេទអាវដៃវែង សំរុងត្រឹមក្បាលជង្គង់ សំរាប់ពាក់ខាងក្រៅ ផលិតអំពីសាច់ក្រណាត់ដែលមានធាតុផ្សំ ហុកសិបប្រាំភាគរយ ប៉ូលីយ៉ែស្ទើរ និងសាមសិបប្រាំភាគរយ កូតុង មានពណ៌ស កបើក ថ្ពេរខុប ឡេវខាងមុខ មានហោប៉ៅបី " ហោប៉ៅមួយ នៅឆ្វេងដៃខាងលើ លើហោប៉ៅមានឱន សញ្ញារបស់ នាយកដ្ឋានកាំកុងត្រូល ខាងក្រោមរូបសញ្ញានេះមានឱនអក្សរឡាតាំង CTL បញ្ជាក់ពីឈ្មោះមន្ទីរពិសោធន៍ (CAMCONTROL Testing Laboratory) ហោប៉ៅពីរទៀតនៅខាងក្រោម ត្រឹមចង្កេះ " ផ្នែកខាង ក្រោយអាវ មាននែកចំកណ្តាល ។

- អាវសំរាប់បំពេញប្រតិបត្តិការ នៅតាមព្រំដែន

ប្រភេទអាវដៃវែងពាក់ខាងក្រៅ ផលិតអំពីសាច់ក្រណាត់មួយរយភាគរយកូតុង មានពណ៌ខៅប្រផេះ កបើក ថ្ពេរខុប មានឡេវរ៉ូតពីក្រោមរហូត ដល់លើ ផ្នែកខាងក្រោមមានក្រវ៉ាត់ចង្កេះសងខាង និង មានហោប៉ៅបួន (ហោប៉ៅពីរនៅខាងក្រោម ដេរបង្កប់តាមថ្ពេរ ឆ្វេងមួយ ស្តាំមួយ និងហោប៉ៅពីរទៀត នៅខាងក្នុងអាវ ផ្នែកមុខ ឆ្វេងមួយ ស្តាំមួយ) ។ ផ្នែកមុខស្តាំដៃ ខាងលើ មានឱនអក្សរថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកខាងក្រោយអាវ មានឱនអក្សរឡាតាំងរាងកោងបន្តិចចំកណ្តាល ថា " CAMCONTROL " ពណ៌ពងក្រសារ ។

- អាវសំរាប់ពិធីការ មាន ពីរ ថ្នាក់ :

- ថ្នាក់ដឹកនាំនាយកដ្ឋាន ថ្នាក់ប្រធានការិយាល័យ និងប្រធានសាខា

ប្រភេទអាវធំដៃវែង ផលិតអំពីសាច់ក្រណាត់តេហ្គាឡែន ពណ៌ពងក្រសារចាស់ កបើក ថ្ពេរខុប ប៉ូលស្មា ជីបក្ជីខាងមុខពីរ មានឡេវធំពីក្រោមរហូតដល់លើពណ៌ទឹកមាស ហោប៉ៅបួន (ហោប៉ៅពីរ ខាងលើ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ ដោយមានឡេវធំពណ៌មាស

ហោប៉ៅពីរទៀត នៅក្រោម មានគំរបរាងចតុកោណកែង ដោយមាន ឡេវធំពណ៌មាស ។ ផ្នែកខាងក្រោយមាន ជីបភ្លីចំនួនពីរ ឆ្វេងមួយ ស្តាំមួយ និងមានផែកចំកណ្តាលនៃអាវ ។

- ថ្នាក់អនុប្រធានការិយាល័យ-អនុសាខា និងមន្ត្រីភ្នាក់ងារ

ប្រភេទអាវដៃវែង ផលិតអំពីសាច់ក្រណាត់តេហ្គាឡែន ពណ៌ពងក្រសារចាស់ កបើក ផ្ទេរឌុប ប៉ូលស្មា ជីបភ្លីខាងមុខពីរ មានឡេវធំពីក្រោមរហូតដល់លើពណ៌ទឹកប្រាក់ ហោប៉ៅបួន (ហោប៉ៅពីរ ខាងលើ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ ដោយមានឡេវធំពណ៌ប្រាក់ ហោប៉ៅពីរទៀត នៅក្រោម មានគំរបរាងចតុកោណកែង ដោយមាន ឡេវធំពណ៌ប្រាក់ ។ ផ្នែកខាងក្រោយមាន ជីបភ្លីចំនួនពីរ ឆ្វេងមួយ ស្តាំមួយ និងមានផែកចំកណ្តាលនៃអាវ ។

អាវសំរាប់ពិធីការនេះ ពាក់ពីខាងក្រៅ ចំពោះអាវខាងក្នុងគឺជាអាវសឺមី ពណ៌ស ដៃវែងភ្ជាប់ក្រវ៉ាត់ក ពណ៌ខៀវទឹកប៊ិច ។

២- មួក ៖

- មួក សំរាប់បំពេញប្រតិបត្តិការនៅព្រំដែន និងនៅទីផ្សារ មាន ៣ ថ្នាក់ ៖

  - ថ្នាក់ដឹកនាំ នាយកដ្ឋាន

    មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខ មានភ្ជាប់រូបព្រះសង្ខា ពណ៌មាស មានក្បាច់ភ្ញីទេស ខិនពណ៌មាស ទំរង់ស្លែងក្របីទ្រព្រះសង្ខា និងមានក្បាំងពណ៌ដូចតួមួក ។ ផ្នែកចំហៀង ខាងឆ្វេង មានខិនអក្សរ ថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកចំហៀងខាងស្តាំ មានខិនអក្សរឡាតាំង ថា " CAMCONTROL " ពណ៌ពងក្រសារ ។

  - ថ្នាក់ការិយាល័យ និងសាខា (បុរស)

    មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខ មានភ្ជាប់រូបព្រះសង្ខា ពណ៌មាស និងមានក្បាំងពណ៌ដូចតួមួក ។ ផ្នែកចំហៀងខាងឆ្វេង មានខិនអក្សរ ថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកចំហៀងខាងស្តាំ មានខិនអក្សរឡាតាំង ថា "CAMCONTROL" ពណ៌ពងក្រសារ ។

  - ថ្នាក់ការិយាល័យ និងសាខា (ស្ត្រី)

    មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខ មានភ្ជាប់រូបព្រះសង្ខាពណ៌មាស មានក្បាំងខាងមុខ និងបទឡើងលើពីចំហៀងព័ទ្ធសងខាងមួក រហូតដល់ក្រោយ ប្រៀបដូចកណ្តាប៉ាន្ត ពណ៌ដូចតួមួក ។ ផ្នែកចំហៀង ខាងឆ្វេងមានខិនអក្សរ ថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកចំហៀង ខាងស្តាំ មានខិនអក្សរឡាតាំង ថា "CAMCONTROL" ពណ៌ពងក្រសារ ។

- ថ្នាក់មន្ត្រីភ្នាក់ងារ (បុរស)

មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ហា ពណ៌ប្រាក់ និងមានក្បាំងពណ៌ដូចតួមួក ។ ផ្នែកចំហៀង ខាងឆ្វេងមានឱនអក្សរ ថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកចំហៀងខាងស្តាំ មានឱនអក្សរឡាតាំងថា " CAMCONTROL " ពណ៌ពងក្រសារ ។

- ថ្នាក់មន្ត្រីភ្នាក់ងារ (ស្ត្រី)

មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ហាពណ៌ប្រាក់ មានក្បាំងខាងមុខ និងបទឡើងលើពីចំហៀងព័ទ្ធសងខាងមួករហូតដល់ក្រោយ ប្រៀបដូចកណ្តាប់វ័ន្ត ពណ៌ដូចតួមួក ។ ផ្នែកចំហៀង ខាងឆ្វេងមានឱនអក្សរថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកចំហៀង ខាងស្តាំ មានឱនអក្សរឡាតាំងថា " CAMCONTROL " ពណ៌ពងក្រសារ ។

មាត្រា ៣ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែ ៩ ៣ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩៩-អនក្រ-បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោកទន្តបណ្ឌិត **វ៉ុលហ្គែង ស្មីតប៊ែគ** (**Wolfgang SCHMIDBERG**) តំណាងអង្គការ **CIM (Central International Migration)** ដែលមានស្នាដៃល្អ និងគុណបំណាច់ក្នុងការជួយអភិវឌ្ឍន៍វិស័យសុខាភិបាល ដោយលោកបានជួយអំណោយកៅអីធ្មេញ ចំនួន១០គ្រឿង ក្នុងឆ្នាំ ១៩៩៦ និង ចំនួន ៣០គ្រឿងទៀត ក្នុងឆ្នាំ ២០០៧ ព្រមទាំងផ្តល់សំភារៈធ្មេញមួយចំនួនទៀត ដល់មហាវិទ្យាល័យ ទន្តវេទសាស្ត្រ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨០៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២00៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ស ម្រេ ច

មាត្រា ១ : ត្រូវបានផ្ទេរក្របខ័ណ្ឌលោក **ស្វាយ សំអុល** ក្រមការដើមខ្សែ ថ្នាក់លេខ ៧ នៃក្របខ័ណ្ឌមន្ត្រីក្រមការ នៅទីស្តីការគណៈរដ្ឋមន្ត្រី ទៅជាក្រមការដើមខ្សែ ថ្នាក់លេខ ៧ នៃក្របខ័ណ្ឌ មន្ត្រីក្រមការក្រសួងមហាផ្ទៃ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ១០ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៨០១ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខតំណែង ជូននាយនគរបាលជាតិជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមុខតំណែងជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១-លោកឧត្តមសេនីយ៍ត្រី ជា សុគន្ធា អត្តលេខ ០១៥២៨ ជា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ។

២-លោកឧត្តមសេនីយ៍ត្រី ឈួរ ឡាធុនី អត្តលេខ ០៣៧៥ ជា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>**កន្លែងទទួល :**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចមាត្រា ៣
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្ស ិ ួយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន នាយទាហាន នាយនគរបាល និងមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការចូលរួម កសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-លោកឧត្តមសេនីយ៍ត្រី	**នួន សាមិន**	ស្នងការនគរបាល ខេត្តកំពង់ចាម
២-លោកវរសេនីយ៍ឯក	**ឆាយ គីមសុន**	ស្នងការរងនគរបាល ខេត្តកំពង់ចាម
៣-លោកជំទាវ	**អឿន អេងឡុង**	នៅរាជធានីភ្នំពេញ
៤-លោកអនុសេនីយ៍ទោ	**លឹម ប៊ុណ្ណា**	មេបញ្ជាការផ្នែកសឹករងស្រុកតំបែរ ខេត្តកំពង់ចាម
៥-លោក	**តាំង ឈីម៉េង**	អាជីវករ ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តកំពង់ចាម
៦-លោក	**ឆា ប៊ុនហ៊ួត**	អាជីវករ ឃុំសូង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម
៧-លោកអនុសេនីយ៍ទោ	**ហ៊ិន ស៊ីថា**	មេបញ្ជាការកងអនុសេនាធំបញ្ជូនសារ
៨-លោក	**សុខ ឆាយ**	អាជីវករ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម
៩-លោកវរសេនីយ៍ឯក	**អ៊ុក សុផាត**	សប្បុរសជន
១០-លោកវរសេនីយ៍ឯក	**ខេន សុវណ្ណ**	សប្បុរសជន
១១-លោកវរសេនីយ៍ឯក	**ឡើក សាមាន**	សប្បុរសជន
១២-លោកវរសេនីយ៍ឯក	**លី សុខហេង**	សប្បុរសជន

១៣-លោកវរសេនីយ៍ឯក	ឈួន	អឿន	សប្បុរសជន
១៤-លោកវរសេនីយ៍ទោ	មាស	សំ	សប្បុរសជន
១៥-លោកវរសេនីយ៍ទោ	ច្រាយ	គិញ	សប្បុរសជន
១៦-លោកវរសេនីយ៍ទោ	ចេន	ឌីដាង	សប្បុរសជន
១៧-លោកវរសេនីយ៍ទោ	អ៊ួង	ឆិម	សប្បុរសជន
១៨-លោកវរសេនីយ៍ទោ	ឈុន	សុខគីម	សប្បុរសជន
១៩-លោកជំទាវ	ខឿ	សុភាព	សប្បុរសជន
២០-លោកជំទាវ	ប្រាក់	សារុំ	សប្បុរសជន
២១-លោកជំទាវ	ជា	សំអឿន	សប្បុរសជន
២២-លោក	គល់	ស៊ីម	សប្បុរសជន
២៣-លោក	អ៊ុច	ធី	សប្បុរសជន
២៤-លោក	ជា	ខណ្ឌ	សប្បុរសជន
២៥-លោក	ឆិត	សារ៉េត	សប្បុរសជន
២៦-លោក	ពៅ	ផល្លី	សប្បុរសជន
២៧-លោក	ឈឹម	សម្បត្តិ	សប្បុរសជន
២៨-លោកអនុសេនីយ៍ឯក	ឡេង	សុខហៀង	សប្បុរសជន
២៩-លោកអនុសេនីយ៍ឯក	ហៀន	វីណា	សប្បុរសជន
៣០-លោកអនុសេនីយ៍ឯក	ប្រាក់	ខណ្ឌដេត	សប្បុរសជន

ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-លោក វរសេនីយ៍ត្រី	គីម	ម៉ាត់ស៊ី	សប្បុរសជន
២-លោក វរសេនីយ៍ទោ	ទៀម	ហេង	សប្បុរសជន
៣-លោក អនុសេនីយ៍ទោ	ហួត	តឿ	សប្បុរសជន

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨០៣ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយការងារ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូននាយទាហាន និងមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

១-លោក	**ឆូ ភាបូ**	សប្បុរសជន
២-លោកស្រីវរសេនីយ៍ទោ	**ស៊ឹម សឿន**	សប្បុរសជន
៣-លោកស្រីវរសេនីយ៍ទោ	**អ៊ុត ជេត**	សប្បុរសជន
៤-លោកវរសេនីយ៍ត្រី	**អាន សិទ្ធ**	វេជ្ជបណ្ឌិត កងពលតូចលេខ ៧០
៥-លោកវរសេនីយ៍ត្រី	**មាយ ចន្ថា**	នាយរងការិយាល័យទី ២ កងពលតូចលេខ ៧០
៦-លោកវរសេនីយ៍ត្រី	**ស៊ិន ស៊ុយ**	នាយរងការិយាល័យហ៊្វីកហ្វឺន កងពលតូចលេខ ៧០
៧-លោកវរសេនីយ៍ត្រី	**ពេជ្រ ឧត្តី**	សប្បុរសជន
៨-លោកវរសេនីយ៍ត្រី	**ម៉ី ប៊ូរ៉ា**	សប្បុរសជន
៩-លោកវរសេនីយ៍ត្រី	**ត្រាំ រ៉ាឌី**	នាយរងការិយាល័យហ៊្វីកហ្វឺន កងពលតូចលេខ ៧០
១០-លោកវរសេនីយ៍ត្រី	**ម៉ូរ ម៉េង**	សប្បុរសជន
១១-លោកវរសេនីយ៍ត្រី	**តាំង ម៉េងហ៊ាង**	សប្បុរសជន

១២-លោកវរសេនីយ៍ត្រី សម្បត្តិ សុធារ៉ាត សប្បុរសជន
១៣-លោកវរសេនីយ៍ត្រី ខ៊ែត ចាន់ណារ៉ា សប្បុរសជន
១៤-លោកអនុសេនីយ៍ឯក ជា សម្បត្តិ សប្បុរសជន
១៥-លោកអនុសេនីយ៍ឯក ចាន់ ស៊ុនណា សប្បុរសជន
១៦-លោកអនុសេនីយ៍ឯក ខួន សុនពិសិទ្ធ សប្បុរសជន
១៧-លោកអនុសេនីយ៍ឯក ហេង លីមអេង សប្បុរសជន
១៨-លោកអនុសេនីយ៍ឯក ថៃ តាំងអៀង សប្បុរសជន
១៩-លោកអនុសេនីយ៍ឯក តាន់ សុផល សប្បុរសជន
២០-លោកអនុសេនីយ៍ឯក ជឿន ជីម ជំនួយការការិយាល័យហ្វីកហ្វីន កងពលតូច លេខ៧០
២១-លោកអនុសេនីយ៍ឯក អៀម គីមហុន ជំនួយការការិយាល័យទី២ កងពលតូច លេខ៧០
២២-លោកអនុសេនីយ៍ឯក សុខ សារ៉េត ជំនួយការការិយាល័យទី២ កងពលតូច លេខ៧០
២៣-លោកអនុសេនីយ៍ឯក ស៊ិន សម្បត្តិ វេជ្ជបណ្ឌិត កងពលតូច លេខ៧០
២៤-លោកអនុសេនីយ៍ឯក ម៊ិន ណាំអៀង ជំនួយការការិយាល័យទី ២ កងពលតូច លេខ៧០
២៥-លោកអនុសេនីយ៍ឯក កែវ ភ័ណា ជំនួយការការិយាល័យទី ៥ កងពលតូច លេខ៧០
២៦-លោកអនុសេនីយ៍ទោ ឡាច ឆាយ វេជ្ជបណ្ឌិត កងពលតូច លេខ៧០
២៧-លោកអនុសេនីយ៍ឯក ចុង ជន សប្បុរសជន
២៨-លោកអនុសេនីយ៍ឯក លេខ សុខហៀង សប្បុរសជន
២៩-លោកអនុសេនីយ៍ទោ គន់ អ៊ូ សប្បុរសជន
៣០-លោកអនុសេនីយ៍ទោ អ៊ួន ចាន់ធូច សប្បុរសជន
៣១-លោកអនុសេនីយ៍ទោ សឿង សិលា សប្បុរសជន
៣២-លោកអនុសេនីយ៍ទោ ប្រាក់ ធូច សប្បុរសជន
៣៣-លោក នួន ប៊ុក សប្បុរសជន
៣៤-លោក មាស ស្តើង អតីតមេឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប
៣៥-លោកស្រី ទ័ក ណាម ក្រុមប្រឹក្សាឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប

ខ-មេដាយប្រាក់ការងារ :

១-លោកស្រី វរសេនីយ៍ត្រី ស៊ិន ជា ឱសថការីឧត្តម កងពលតូចលេខ៧០
២-លោក អនុសេនីយ៍ឯក សៀ ដូរ៉ាំង គីលានុប្បដ្ឋាកបឋម កងពលតូចលេខ៧០
៣-លោក អនុសេនីយ៍ឯក ហាក់ ទ្រី គីលានុប្បដ្ឋាកបឋម កងពលតូចលេខ៧០
៤-លោក អនុសេនីយ៍ឯក មាស សុធី គីលានុប្បដ្ឋាកបឋម កងពលតូចលេខ៧០
៥-លោក អនុសេនីយ៍ឯក ឯក ផាន់ណា មេបញ្ជាការរងកងអនុសេនាធំស៊ើបការណ៍
៦-លោក អនុសេនីយ៍ទោ អ៊ុង សោភ័ណ្ឌ គីលានុប្បដ្ឋាកបឋម កងពលតូចលេខ ៧០
៧-លោក អនុសេនីយ៍ទោ និត្យ បូរ៉ា គីលានុប្បដ្ឋាកបឋម កងពលតូចលេខ ៧០

៨-លោក អនុសេនីយ៍ទោ	ស៊ឹម	ប៊ុណ្ណា	គីលានុប្បដ្ឋាកបឋម កងពលតូចលេខ ៧០
៩-លោក អនុសេនីយ៍ទោ	កែវ	សុធី	គីលានុប្បដ្ឋាកបឋម កងពលតូចលេខ ៧០
១០-លោក នាយចំណង់	ហ៊ុល	ភូរិន្ទ	គីលានុប្បដ្ឋាកបឋម កងពលតូចលេខ ៧០
១១-លោកស្រី ពលបាលត្រី	មាស	សោភា	គីលានុប្បដ្ឋាកបឋម កងពលតូចលេខ ៧០

គ-មេជាងសិល្បការងារ :

១-លោក អនុសេនីយ៍ឯក	ថោង	សុខាភារុ	ជំនួយការការិយាល័យហ្វឹកហ្វឺន កងពលតូចលេខ៧០
២-លោក ព្រឹន្ទបាលទោ	គង់	វ៉ាន់នី	បុគ្គលិកឯកសារ ការិយាល័យហ្វឹកហ្វឺន កងពលតូចលេខ៧០

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨០៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី
៚
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ** ជូន **Mr. Hans Stirnemann** សមាជិកអង្គការ **Mine-Ex** ដែលបានផ្តល់អំណោយជាម៉ាស៊ីនក្រឡឹង និងម៉ាស៊ីន ប្រែស ធុនទំនើប ជូនរោងចក្រផលិត ឧបករណ៍សិប្បនិម្មិត ICRC បឹងត្របែក ។

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៩ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៨០៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

ពពួ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន **Mr. Joël Nininger** ប្រធានកម្មវិធីស្តារលទ្ធភាពពលកម្ម កាយសម្បទា នៃអង្គការ **ICRC** ប្រចាំកម្ពុជា ដែលបានផ្តល់អំណោយជាម៉ាស៊ីនក្រឡឹង និងម៉ាស៊ីនប្រៀស ធុនទំនើប ជូនរោងចក្រផលិតឧបករណ៍សិប្បនិម្មិត ICRC បឹងត្របែក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨០៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

១៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **ម៉ា ច័ន្ទណារាត** អ្នកសម្របសម្រួលបច្ចេកទេស សំរាប់ កម្មវិធីស្តារលទ្ធភាពពលកម្ម កាយសម្បទា ប្រចាំកម្ពុជា នៃអង្គការ ICRC និងជាប្រធានរោងចក្រផលិត ឧបករណ៍សិប្បនិម្មិត ដែលមានស្នាដៃល្អក្នុងការទំនាក់ទំនងស្វែងរកអំណោយជាម៉ាស៊ីនក្រឡឹង និងម៉ាស៊ីន ព្រៀស ធុនទំនើប បំពាក់ជូនរោងចក្រផលិត ឧបករណ៍សិប្បនិម្មិត ICRC បឹងត្របែក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវ អនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

[illegible] សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៨០៧...អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនព្រះគ្រូ **ហាក់ សុខគឿន** សប្បុរសជនរស់នៅភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលផ្សេងៗ មានដូចជា ផ្លូវ ព្រះវិហារ អណ្តូងទឹក ប៉ុស្តិ៍នគរបាល និង ឧបត្ថម្ភប្រជាពលរដ្ឋក្រីក្រ ។ល។ នៅក្នុងមូលដ្ឋាន ស្រុកស្អាង ខេត្តកណ្តាល ដោយចំណាយអស់ទឹកប្រាក់ សរុបចំនួន ៥១.០២៥ ដុល្លារ និង ១៤០.០០០.០០០ រៀល ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ... ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៨០៨..អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើ របស់ឯកឧត្តម ញ៉ឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី

សំរេច

មាត្រា ១ :ត្រូវបានបំពាក់ **មេដាយមាស ស្ថាបនាជាតិ** ជូនសប្បុរសជនជនជាតិជប៉ុន ចំនួន ០២រូប ដែលបានយកអស់ពីកម្លាំងកាយចិត្តបានជួយឧបត្ថម្ភថវិកាដែលមានទឹកប្រាក់សរុប៥០.០០០ដុល្លារអាមេរិកក្នុងការសាងសង់សាលារៀនថ្មីចំនួន២ខ្នង នៅខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម:

១-លោក **កាស់ស៊ូ ម៉ាត់ស៊ុម៉ូតូ** (KASUO MATSUMOTO)

២-លោក **ហាសេកាវ៉ា យ៉ាស៊ុតូស៊ី** (HASEGAWA YASUTOSHI)

មាត្រា ២ :រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានី... ខែ តុលា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

...សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥០៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងថ្នាក់ដឹកនាំនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី សុខ នី អត្តលេខ ០៤០៩ ពីអនុប្រធានលេខាធិការដ្ឋាន ទៅជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ១០ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៩១០..អនក្រ.-តត

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឃឹម ឡាំង** ឋានន្តរសក្តិ វរសេនីយ៍ឯក នៃក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ ជាអភិបាលខណ្ឌសាលាក្រៅ ក្រុងប៉ៃលិន ។

មាត្រា ២ : លោក **យឹម ឡារិន** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួន ត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ១៧ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..៤៦៥.....សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០៧

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ២០០៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក.ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែ ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០៣ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

លេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax 855-23-427 798

- បានឃើញក្រឹត្យលេខ៥៧ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញនាំចូល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលបានប្រកាស ឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ
- បានឃើញពិធីសារស្តីពីការអនុវត្តនាមវលី នៃតារាងពន្ធគយស៊ីចង្វាក់គ្នារបស់អាស៊ាន ដែលចុះហត្ថលេខា ដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធ និងអាករគយលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេស លើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

<u>សម្រេច</u>

ប្រការ ១ : ដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០០៧ ដូចមានភ្ជាប់ជាមួយនេះ ដែលបានរៀបចំដោយអនុលោមតាមប្រព័ន្ធស៊ីចង្វាក់ នៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ និងស្របទៅតាមតារាងពន្ធគយ នៃប្រព័ន្ធស៊ីចង្វាក់របស់អាស៊ាន (AHTN 2007) ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៧ តទៅ ។

ប្រការ ២ : រាល់មុខទំនិញនាំចេញ នាំចូលត្រូវជាប់ពន្ធនាំចូល អាករពិសេស អាករលើតម្លៃបន្ថែម និងអាករនាំចេញ ដូចមានចែងលំអិតក្នុងតារាងពន្ធគយនេះ ។

ប្រការ ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ ខាងមុខនេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ខេត្តក្រុង "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្ម
- ទីចាត់ការគយ និងរដ្ឋាករ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ផ្នែកទី XVIII

ឧបករណ៍ និងបរិធានអុបទិកថតរូប ឬភាពយន្ត ឧបករណ៍សំរាប់វាស់វែង សំរាប់ត្រួតពិនិត្យ ឬសំរាប់ចិតាគ និងឧបករណ៍បរិធានវេជ្ជសាស្ត្រវះកាត់ គ្រឿងនាឡិកា ឧបករណ៍ភ្លេង ភាគ និងគ្រឿងបន្លាស់បន្សំនៃឧបករណ៍ និងគ្រឿងទាំងនោះ

ជំពូកទី ៩០

ឧបករណ៍ និងបរិធានអុបទិកថត ឬភាពយន្ត ឧបករណ៍សំរាប់វាស់វែង សំរាប់ត្រួតពិនិត្យ ឬសំរាប់ចិតាគ និង ឧបករណ៍បរិធានវេជ្ជសាស្ត្រវះកាត់ ភាគ និងគ្រឿងបន្លាស់បន្សំ នៃ ឧបករណ៍ និងគ្រឿងទាំងនោះ

កំណត់សំគាល់ :

1- ជំពូកនេះមិនរាប់បញ្ចូល :

Section XVIII

OPTICAL, PHOTOGRAPHIC, CINEMATOGRAPHIC, MEASURING, CHECKING, PRECISION, MEDICAL OR SURGICAL INSTRUMENTS AND APPARATUS; CLOCKS AND WATCHES; MUSICAL INSTRUMENTS; PARTS AND ACCESSORIES THEREOF

Chapter 90

Optical, photographic, cinematographic, measuring, checking, precision, medical or surgical instruments and apparatus; parts and accessories thereof

Notes.

This Chapter does not cover :

(a)	បរិក្ខារសំរាប់ការប្រើប្រាស់នៅក្នុងម៉ាស៊ីន ឬក្នុងបច្ចេកទេសធ្វើអំពីកៅស៊ូស៊ិតក្រៅពីកៅស៊ូរឹង (ទីតាំងលេខ ៤០.១៦) ធ្វើអំពីស្បែកធម្មជាតិ ឬស្បែកផ្សំ (ទីតាំងលេខ ៤២.០៤) ធ្វើអំពីវត្ថុធាតុគណ្ឌ (ទីតាំងលេខ ៥៩.១១) ។	Articles of a kind used in machines, appliances or for other technical uses, of vulcanised rubber other than hard rubber (heading No. 40.16), of leather or of composition leather (heading No. 42.04) or of textile material (heading No. 59.11);
(b)	ខ្សែក្រវាត់ការពារ និងបរិក្ខារការពារផ្សេងទៀតដែលធ្វើពីវត្ថុធាតុវាយនភ័ណ្ឌក្នុងគោលបំណង ការពាររាងកាយដោយភាពយឺតរបស់វា (ឧទា. ខ្សែក្រវាត់សម្ពត់ ស្បៃរុំទ្រូង ស្បៃរឹតពោះ ស្បៃរុំសន្លាក់ ឬសាច់ដុំ)នៃផ្នែក XI ។	Supporting belts or other support articles of textile material, whose intended effect on the organ to be supported or held derives solely from their elasticity (for example, maternity belts, thoracic support bandages, abdominal support bandages, supports for joints or muscles) (Section XI);
(c)	ផលិតផលមិនឆាំកំដៅនៃទីតាំងលេខ ៦៩.០៣ ។ បរិក្ខារសេរ៉ាមិចសំរាប់ការប្រើប្រាស់ក្នុងមន្ទីរពិសោធន៍គីមី ឬប្រើប្រាស់បច្ចេកទេសផ្សេងទៀតនៃទីតាំងលេខ ៦៩.០៩	Refractory goods of heading No. 69.03; ceramic wares for laboratory, chemical or other technical uses, of heading No. 69.09;
(d)	កញ្ចក់ឆ្លុះធ្វើអំពីកែវដែលគ្មានច្នៃជាគ្រឿងអុបទិកនៃទីតាំងលេខ ៧០.០៩ ព្រមទាំងកញ្ចក់ឆ្លុះធ្វើអំពីលោហៈធម្មតា ឬលោហៈមានតំលៃហើយដែលគ្មានទ្រង់ទ្រាយវត្ថុធាតុអុបទិកនៃទីតាំង លេខ ៨៣.០៦ ឬជំពូក ៧១។	Glass mirrors, not optically worked, of heading No. 70.09, or mirrors of base metal or of precious metal, not being optical elements (heading No. 83.06 or Chapter 71);
(e)	បរិក្ខារធ្វើអំពីកែវនៃទីតាំងលេខ ៧០.០៧, ៧០.០៨, ៧០.១១, ៧០.១៤, ៧០.១៥ ឬ ៧០.១៧។	Goods of heading No. 70.07, 70.08, 70.11, 70.14, 70.15 or 70.17;
(f)	គ្រឿងសំរាប់ប្រើប្រាស់ទូទៅតាមអត្ថន័យកំណត់សំគាល់លេខ ២ នៃផ្នែក XV ធ្វើអំពីលោហធាតុ ធម្មតា "ផ្នែក XV" និងបរិក្ខារប្រហាក់ប្រហែល ធ្វើអំពីវត្ថុធាតុប្លាស្ទិក ជំពូកទី ៣៩ ។	Parts of general use, as defined in Note 2 to Section XV, of base metal (Section XV) or similar goods of plastics (Chapter 39);

(g) ស្នប់ចែកប្រេងដែលមានប្រដាប់វាស់វែងនៃទីតាំងលេខ ៨៤.១៣ ជញ្ជីងប៉ុង ឬ ជញ្ជីងសំរាប់ផ្ទៀង និងសំរាប់វត្ថុថ្លឹងដោយម៉ាស៊ីនព្រមទាំងឧបករណ៍កូនជញ្ជីង ដែលបង្ហាញដាច់ពីគ្នា "ទីតាំង លេខ ៨៤.២៣"។ ឧបករណ៍សំរាប់លើកដាក់ "ទីតាំងលេខ ៨៤.២៥ ទៅ ៨៤.២៨"។

Pumps incorporating measuring devices, of heading No. 84.13; weight-operated counting or checking machinery, or separately presented weights for balances (heading No. 84.23); lifting or handling machinery (headings Nos. 84.25 to 84.28);

ប្រដាប់កាត់គ្រប់ប្រភេទសំរាប់កាត់ក្រដាស ឬកាតុង "ទី តាំងលេខ ៨៤.៤១"។ គ្រឿងយន្តពិសេសសំរាប់ម្ជុលតំរូវផែកដែល ត្រូវក្រឡឹងឬធ្វើឬសំរាប់ម្ជុលតំរូវ ឧបករណ៍នៅលើម៉ាស៊ីន ឧបករណ៍ នោះបីជាមាន

paper or paperboard cutting machines of all kinds (heading No. 84.41); fittings for adjusting work or tools on machine tools, of heading No. 84.66, including fittings

គ្រឿងអុបទិកសំរាប់អាននៃទីតាំងលេខ ៨៤.៦៦ ក្រៅពីគ្រឿងអុបទិកសុទ្ធសាធ កែវសំរាប់តំរង់រកចំណុចកណ្តាល ឬកបន្ទាត់ត្រង់។ ម៉ាស៊ីនគិតលេខនៃទីតាំង លេខ៨៤.៧០។

with optical devices for reading the scale (for example, "optical" dividing heads) but not those which are in themselves essentially optical instruments (for example, alignment telescopes); calculating machines (heading No. 84.70);

ឧបករណ៍សំរាប់បន្ធូរខ្យល់សន្ទះ ឬឧបករណ៍សំរាប់របឺណេទីតាំងលេខ៨៤.៨១

valves or other appliances of heading No. 84.81;

(h) ចង្កៀងបញ្ចាំងរកមើល ចង្កៀងបញ្ចាំងបំភ្លឺប្រភេទប្រើប្រាស់សំរាប់ទោចក្រយាន ឬយានយន្ត "ទីតាំងលេខ៨៥.១២"។ ចង្កៀងអគ្គិសនីយួរបាននៃទីតាំងលេខ ៨៥.១៣ ។

Searchlights or spotlights of a kind used for cycles or motor vehicles (heading No. 85.12); portable electric lamps of heading No. 85.13;

ឧបករណ៍ថតសំលេងភាពយន្តថត និង ផលិតឡើងវិញ ឬឧបករណ៍សំរាប់ថត សំលេងឡើងវិញ "ទីតាំងលេខ ៨៥.១៩ ឬ ៨៥.២០"។

cinematographic sound recording, reproducing or re-recording apparatus (heading No. 85.19 or 85.20);

ក្បាល សំលេងទីតាំងលេខ ៨៥.២២ ។ ម៉ាស៊ីនវីដេអូថតរូបភាពហ្នឹង និងម៉ាស៊ីន វីដេអូថតផ្សេងទៀតទីតាំង លេខ៨៥.២៥ ។

sound-heads (heading No. 85.22); still image video cameras and other video camera recorders (heading No. 85.25);

	ឧបករណ៍វិទ្យុរ៉ាដា និង វិទ្យុស្ទង់ទឹក រ៉ាដា ឧបករណ៍វិទ្យុនាវាចរណ៍ និងឧបករណ៍វិទ្យុទូរបញ្ជានៃទីតាំងលេខ ៨៥.២៦ ។ ឧបករណ៍ត្រួតពិនិត្យលេខ ៨៥.៣៧ ។	radar apparatus, radio navigational aid apparatus or radio remote control apparatus (heading No. 85.26); numerical control apparatus of heading 85.37
(ij)	ចង្កៀងបញ្ចាំងរកមើល ឬចង្កៀងបញ្ចាំងផ្សេងទៀតនៃទីតាំងលេខ ៩៤.០៥។	Searchlights or spotlights of heading No. 94.05;
(k)	បរិក្ខារនៃជំពូកទី ៩៥ ។	Articles of Chapter 95;
(l)	រង្វាស់រង្វាល់ចំណុះដែលចាត់ថ្នាក់ជាមួយនឹងវត្ថុស្នាដៃនៃវត្ថុជាគ្រឿងផ្សំ ។	Capacity measures, which are to be classified according to their constituent material; or
(m)	បូប៊ីន និង ទំប្រហាក់ប្រហែល "ចាត់ថ្នាក់ទៅតាមវត្ថុធាតុផ្សំ ឧទាហរណ៍ទីតាំងលេខ ៣៩.២៣ នៃផ្នែក XV ។	Spools, reels or similar supports (which are to be classified according to their constituent material, for example, in heading No. 39.23 or Section XV).
2-	តាមអត្ថន័យកំណត់សំគាល់ ១ ខាងលើនេះភាគ ផ្នែកនិងគ្រឿងបន្ទាប់បន្សំសំរាប់ម៉ាស៊ីនឧបករណ៍ឬប្រដាប់ប្រដានៃជំពូកនេះត្រូវចាត់ថ្នាក់ឱ្យសមស្របទៅតាមវិធានខាងក្រោមនេះ:	Subject to Note 1 above, parts and accessories for machines, apparatus, instruments or articles of this Chapter are to be classified according to the following rules :
(a)	ភាគ និងគ្រឿងបន្ទាប់បន្សំដែលជាបរិក្ខារថែងនៅក្នុងទីតាំងណាមួយនៃជំពូកនេះឬនៃជំពូកទី ៨៤, ៨៥ ឬ ៩១ "ក្រៅពីទីតាំងលេខ ៨៤.៨៥, ៨៥.៤៨ ឬ ៩០.៣៣" គ្រប់ករណីទាំងអស់ត្រូវចាត់ថ្នាក់ទៅតាមទីតាំងសមស្របរបស់វា។	Parts and accessories which are goods included in any of the headings of this Chapter or of Chapter 84, 85 or 91 (other than heading No. 84.85, 85.48 or 90.33) are in all cases to be classified in their respective headings;

(b) ភាគ និងគ្រឿងបន្លាស់ផ្សេងទៀតបានត្រូវស្គាល់ជាក់ថាសំរាប់តែប្រើប្រាស់ចំពោះម៉ាស៊ីន ឧបករណ៍ និងបរិធានដោយឡែកណាមួយឬក៏សំរាប់ប្រើប្រាស់ចំពោះម៉ាស៊ីន ឧបករណ៍ ឬ បរិធានច្រើននៃស្ថានភាពជាមួយគ្នាទោះជាទីតាំងលេខ៩០.១០, ៩០.១៣, ៩០.៣១ ។ ផ្នែក និងគ្រឿងបន្លាស់ក្រៅពីគ្រឿងដែលបានចែងថាសំរាប់ម៉ាស៊ីន និងបរិធាន និងឧបករណ៍ទាំងនេះ ត្រូវចាត់ថ្នាក់ក្នុងស្ថានភាពពាក់ព័ន្ធទៅនឹងម៉ាស៊ីន ឧបករណ៍បរិធាននោះឯង ។

Other parts and accessories, if suitable for use solely or principally with a particular kind of machine, instrument or apparatus, or with a number of machines, instruments or apparatus of the same heading (including a machine, instrument or apparatus of heading No. 90.10, 90.13 or 90.31) are to be classified with the machines, instruments or apparatus of that kind;

(c) ភាគ និងគ្រឿងបន្លាស់ផ្សេងទៀតត្រូវចាត់ថ្នាក់នៃ"ទីតាំងលេខ ៩០.៣៣" ។

All other parts and accessories are to be classified in heading No. 90.33.

3- បណ្តាបទបញ្ញត្តិនៃកំណត់សំគាល់លេខ 4 នៃផ្នែក XVI នឹងត្រូវអនុវត្តដែរសំរាប់ជំពូកនេះ។

The provisions of Note 4 to Section XVI apply also to this Chapter.

4- ទីតាំងលេខ ៩០.០៥ មិនរាប់បញ្ចូលនូវកែវយឺត តំរង់សំរាប់អាវុធ កែវយឺតឆ្លុះសំរាប់នាវាមុជ ទឹក ឬរថក្រោះ ឬកែវយឺតសំរាប់ម៉ាស៊ីន បរិធាន ឬឧបករណ៍នៃជំពូកនេះ ឬនៃផ្នែក XVI នៃទីតាំងលេខ ៩០.១៣ ។

Heading No. 90.05 does not apply to telescopic sights for fitting to arms, periscopic telescopes for fitting to submarines or tanks, or to telescopes for machines, appliances, instruments or apparatus of this Chapter or Section XVI; such telescopic sights and telescopes are to be classified in heading No. 90.13.

5- ម៉ាស៊ីន បរិធាន ឬឧបករណ៍អុបទិកសំរាប់វាស់វែង ឬត្រួតពិនិត្យហេតុដែលអាចឡើងទៅទីតាំងលេខ ៩០.១៣ និង ៩០.៣១ ផងដែរនោះ ត្រូវចាត់ថ្នាក់ទៅទីតាំងលេខ ៩០.៣១ ។

Measuring or checking optical instruments, appliances or machines which, but for this Note, could be classified both in heading No. 90.13 and in heading No. 90.31 are to be classified in heading No. 90.31.

6- គោលបំណងនៃទីតាំង៩០.២១ ពាក្យថា "បរិធានអូតូភីឌិក" មានន័យថាបរិធានសម្រាប់ :

- ការពារ ឬភ្ជាប់ជាមួយគ្នា ឬ
- ទ្រ ឬភ្ជាប់ផ្នែកខ្លះនៃតួអាស្រ័យដោយជម្ងឺ ឬដំណើរការមុខរបួស

For the purposes of heading 90.21, the expression "orthopaedic appliances" means appliances for:

- Preventing or correcting bodily deformities; or
- Supporting or holding parts of the body following an illness, operation or injury.

- បរិធានអ័រតូពេឌិករួមបញ្ចូលទាំងប្រដាប់ពាក់ក្នុងជើងរៀបចំឡើងទៅតាមលក្ខខណ្ឌភ្ជាប់ទៅនឹងអ័រតូពេឌិកដែលផ្តល់ឱ្យទោះជា (១). ប្រើប្រាស់ក្នុងការវាស់ (២). ការបង្កើតម៉ាស ទោះបង្ហាញតែមួយ និងមិនទាំងគូ ទោះជាបង្កើតឡើងត្រូវតាមជើងក៏ដោយ ។

Orthopaedic appliances include footwear and special insoles designed to correct orthopaedic conditions, provided that they are either (1) made to measure or (2) mass-produced, presented singly and not in pairs and designed to fit either foot equally.

7- ទីតាំងលេខ ៩០.៣២ រួមបញ្ចូលតែ :

Heading No. 90.32 applies only to :

(a) ឧបករណ៍ បរិធានសំរាប់និយ័តកម្មសន្ទនិយស្វ័យប្រវត្តិ ឬត្រួតពិនិត្យស្វ័យប្រវត្តិនៃសីតុណ្ហភាព ទោះជាដំណើរការរបស់វាបានត្រូវប្រើដោយវិធីបាតុភូតអគ្គិសនីប្រែប្រួលនៃទំហំជាមួយនឹងកត្តាត្រូវការណាក៏ដោយ ។

Instruments and apparatus for automatically controlling the flow, level, pressure or other variables of liquids or gases, or for automatically controlling temperature, whether or not their operation depends on an electrical phenomenon which varies according to the factor to he automatically controlled; and

(b) ឧបករណ៍និយ័តស្វ័យប្រវត្តិនៃទំហំអគ្គិសនីព្រមទាំងឧបករណ៍និយ័តស្វ័យប្រវត្តិនៃទំហំផ្សេង ទៀតដែលប្រតិបត្តិការផ្អែកទៅលើបាតុភូតអគ្គិសនីប្រែប្រួលដោយកត្តាកំណត់បាន និងរក្សានូវតម្លៃទល់នឹងការរំខានផ្សេងៗ ដោយមានរបោកឬការវាស់ទៅតាមតម្លៃពិតរបស់វា .

Automatic regulators of electrical quantities, and instruments or apparatus for automatically controlling non-electrical quantities the operation of which depends on an electrical phenomenon varying according to the factor to be controlled, which are designed to bring this factor to, and maintain it at, a desired value, stabilised against disturbances, by constantly or periodically measuring its actual value.

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	

90.01		សរសៃអុបទិក និងបាច់សរសៃអុបទិក តាមអត្ថន័យសរសៃអុបទិកក្រៅពីសរសៃ ដែលនៅទី តាំងលេខ ៨៥.៤៤ វត្ថុធាតុប៉ូឡារីសជាស្លឹកឬជាផ្ទាំ ។ កែវឡង់ទី បញ្ចូលកែវដាក់ភ្នែក កែវព្រីស្ម កញ្ចក់ និង វត្ថុធាតុអុបទិកធ្វើអំពីវត្ថុធាតុគ្រប់ប្រភេទបំពាក់ឡើងក្រៅពីកែវមិនទាន់ច្នៃជាអុបទិក។	**Optical fibres and optical fibre bundles; optical fibre cables other than those of heading No.85.44; sheets and plates of polarising material; lenses (including contact lenses), prisms, mirrors and other optical elements, of any material, unmounted, other than such elements of glass not optically worked.**						
	9001.10	- សរសៃអុបទិក ការ និងបាច់សរសៃអុបទិក :	- Optical fibres, Optical fibre bundles and cables :						
	9001.10.10	- - សំរាប់ទូរគមនាគមន៍ និងការប្រើប្រាស់អគ្គិសនីផ្សេងទៀត	- - For telecommunications and other electrical use	kg	35	0	10	0	
	9001.10.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
	9001.20.00	- សន្លឹក និងបន្ទះនៃវត្ថុធាតុ ប៉ូឡារីសេ	- Sheets and plates of polarising material	kg	35	0	10	0	
	9001.30.00	- កែវដាក់ក្នុងភ្នែក	- Contact lenses	u	7	0	10	0	
	9001.40.00	- កញ្ចក់វ៉ែនតាអំពីកែវ	- Spectacle lenses of glass	u	15	0	10	0	
	9001.50.00	- កញ្ចក់វ៉ែនតាអំពីវត្ថុធាតុផ្សេងទៀត	- Spectacle lenses of other materials	u	15	0	10	0	
	9001.90	- ផ្សេងទៀត :	- Other :						
	9001.90.10	- - សំរាប់កាមេរ៉ាថតរូប និងថតភាពយន្ត និងម៉ាស៊ីនបញ្ចាំង ភាពយន្ត ឬ រូបថត ឬម៉ាស៊ីនបញ្ចាំងពន្លឺ ។	- - For photographic or cinematographic cameras or projectors	kg	35	0	10	0	
	9001.90.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
90.02		កញ្ចក់ឡង់ទី កែវព្រីស្ម កញ្ចក់ឆ្លុះ និងវត្ថុអុបទិក ធ្វើអំពីវត្ថុធាតុគ្រប់ប្រភេទបំពាក់ឡើង ហើយសំរាប់ឧបករណ៍ ឬបរិធានក្រៅពីឧបករណ៍បរិធានធ្វើអំពីកែវមិនទាន់ច្នៃជាអុបទិក។	**Lenses, prisms, mirrors and other optical elements, of any material, mounted, being parts of or fitting for instruments or apparatus, other than such elements of glass not optically worked.**						
		- កញ្ចក់អុបហ្សិកទីហ្វ :	- Objective lenses :						
	9002.11	- - សំរាប់កាមេរ៉ា ម៉ាស៊ីនបញ្ចាំងរូប ឬប្រដាប់ពង្រីក ឬបង្រួមរូប :	- - For cameras, projectors or photographic enlargers or reducers :						
	9002.11.10	- - - ម៉ាស៊ីនបញ្ចាំងភាពយន្ត	- - - Cinematographic projector	kg	35	0	10	0	

	9002.11.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
	9002.19.00	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
	9002.20	- ឧបករណ៍ចម្រោះពន្លឺ :	- Filters :						
	9002.20.10	- - សំរាប់ម៉ាស៊ីនថតរូប ឬម៉ាស៊ីនបញ្ចាំងរូប	- - For cinematographic projectors	kg	35	0	10	0	
	9002.20.20	- - ម៉ាស៊ីនថតភាពយន្ត ម៉ាស៊ីនថតរូប និងម៉ាស៊ីនបញ្ចាំងផ្សេងទៀត	- - For cinematographic cameras, photographic cameras and other projectors	kg	35	0	10	0	
	9002.20.30	- - កែវយឺត ឬ អតិសុខុមទស្សន៍/កែវពង្រីក	- - For telescopes or microscopes	kg	35	0	10	0	
	9002.20.90	- - ឧបករណ៍ចម្រោះពន្លឺផ្សេងទៀត	- - Other filters	kg	35	0	10	0	
	9002.90	- ផ្សេងទៀត :	- Other :						
	9002.90.10	- - កញ្ចក់ឆ្លុះចិត្ត ព្រីស សំរាប់ម៉ាស៊ីនថតរូប ឬម៉ាស៊ីនបញ្ចាំងរូប	- - Lenses and prisms for lighthouses or beacons	kg	35	0	10	0	
	9002.90.20	- - ម៉ាស៊ីនបញ្ចាំងភាពយន្ត	- - For cinematographic projectors	kg	35	0	10	0	
	9002.90.30	- - ម៉ាស៊ីនថតភាពយន្ត ម៉ាស៊ីនថតរូប និងម៉ាស៊ីនបញ្ចាំងផ្សេងទៀត	- - For cinematographic cameras, photographic cameras and other projectors	kg	35	0	10	0	
	9002.90.40	- - សំរាប់ឧបករណ៍ពិសោធ និងវះកាត់	- - For medical and surgical instruments	kg	35	0	10	0	
	9002.90.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
90.03		ជងវ៉ែនតា វ៉ែនតាការពារភ្នែក ឬបរិក្ខារប្រហាក់ប្រហែលនឹងភាគរបស់វា ។	**Frames and mountings for spectacles, goggles or the like, and parts thereof.**						
		- ជងវ៉ែនតា :	- Frames and mountings :						
	9003.11.00	- - ធ្វើពីផ្លាស្ទិក	- - Of plastics	u	15	0	10	0	
	9003.19.00	- - ធ្វើពីវត្ថុធាតុផ្សេងទៀត	- - Of other materials	u	15	0	10	0	
	9003.90.00	- ភាគ បំណែក	- Parts	kg	15	0	10	0	
90.04		វ៉ែនតា វ៉ែនតាការពារភ្នែក និងវ៉ែនតាប្រហាក់ប្រហែល វ៉ែនតាតំរូវភ្នែក និងការពារភ្នែក ឬផ្សេងទៀត ។	**Spectacles, goggles and the like, corrective, protective or others**						
	9004.10.00	- វ៉ែនតាការពារពន្លឺព្រះអាទិត្យ	- Sunglasses	u	15	0	10	0	

	9004.90	- ផ្សេងទៀត :	- Other :						
	9004.90.10	- - វ៉ែនតាកែតម្រូវភ្នែក	- - Corrective spectacles	u	7	0	10	0	
	9004.90.20	- - វ៉ែនតាតម្រូវនិងការពារភ្នែក	- - Corrective goggles	u	7	0	10	0	
	9004.90.50	- - វ៉ែនតាការពារ	- - Protective goggles	u	7	0	10	0	
	9004.90.90	- - ផ្សេងទៀត	- - Other	u	15	0	10	0	
90.05		កែវយឺត កែវយឺតវែង កែវយឺតតារាសាស្ត្រ កែវយឺតអុបទិក"តេឡេស្កុប" និងគ្រឿងរបស់វា គ្រឿងប្រដាប់តារាសាស្ត្រ ផ្សេងទៀត និងជើងរបស់វាក្រៅពីបរិធានវិទ្យុតារាសាស្ត្រ។	**Binoculars, monoculars, other optical telescopes, and mountings therefor; other astronomical instruments and mountings therefor, but not including instruments for radio-astronomy.**						
	9005.10.00	- កែវយឺតប្រើភ្នែកពីរ	- Binoculars	u	35	0	10	0	
	9005.80	- ឧបករណ៍ផ្សេងទៀត :	- Other instruments :						
	9005.80.10	- - ឧបករណ៍តារាសាស្ត្រ មិនរាប់បញ្ចូលឧបករណ៍សំរាប់វិទ្យុតារាសាស្ត្រ ។	- - Astronomical instruments, excluding instruments for radio-astronomy	u	35	0	10	0	
	9005.80.90	- - ផ្សេងទៀត	- - C	u	35	0	10	0	
	9005.90	- បំណែក និងគ្រឿងបន្លាស់បន្សំ (រាប់បញ្ចូលទាំងជើងរបស់វា) :	- Parts and accessories (including mountings):						
	9005.90.10	- - ឧបករណ៍តារាសាស្ត្រ មិនរាប់បញ្ចូលឧបករណ៍សំរាប់វិទ្យុតារាសាស្ត្រ ។	- - for Astronomical instruments, excluding instruments for radio-astronomy	kg	35	0	10	0	
	9005.90.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
90.06		ម៉ាស៊ីនថតរូប បរិធាន និងគ្រឿងព្រមទាំងចង្កៀង និងបំពង់សំរាប់ផលិតភ្លើង កន្លែងសំរាប់ថតរូប លើកលែងតែចង្កៀងនិងបំពង់ដោះបន្ទុកនៃទីតាំងលេខ ៨៥.៣៩	**Photographic (other than cinematographic) cameras; photographic flashlight apparatus and flashbulbs other than discharge lamps of heading No. 85.39.**						
	9006.10	- ការម៉េរ៉ាប្រភេទប្រើប្រាស់សំរាប់រៀបចំបន្ទះ ឬស៊ីឡាំងបោះពុម្ព	- Cameras of a kind used for preparing printing plates or cylinders						
	9006.10.10	- - ឧបករណ៍ផ្លូវរូបភាពដោយឡាស៊ែរ ((អាយធីអេ/២ (អេអេស២))	- - Laser photo plotters [ITA/2 (AS2)]	u	35	0	10	0	
	9006.10.90	- - ផ្សេងទៀត	- - Other	u	35	0	10	0	

	9006.30.00	- កាមេរ៉ាសំរាប់ប្រើក្នុងទឹក អង្កេតលើអាកាស ឬសំរាប់ពិនិត្យនិងវះកាត់នៃសរីរាង្គខាងក្នុង កាមេរ៉ាប្រៀបធៀបសំរាប់និតិវេជ្ជសាស្ត្រ ឬឧក្រិដ្ឋវិទ្យា ។	- Cameras specially designed for underwater use, for aerial survey or for medical or surgical examinations of internal organs; comparison cameras for forensic or criminological purposes:	u	35	0	10	0	
	9006.40.00	- កាមេរ៉ាបោះពុម្ពភ្លាមៗ	- Instant print cameras	u	35	10	10	0	
		- កាមេរ៉ាផ្សេងទៀត :	- Other cameras :						
	9006.51.00	- - ថតតាមរយៈអុបហ្សិកទីហ្វសំរាប់ហ្វីលជារ៉ូឡូដែលមានទទឹងមិនលើស ៣៥ ម.ម	- - With a through-the-lens viewfinder (single lens reflex (SLR)), for roll film of a width not exceeding 35 mm	u	35	10	10	0	
	9006.52.00	- - ផ្សេងទៀត សំរាប់ហ្វីលជារ៉ូឡូ ដែលមានទទឹងតិចជាង ៣៥ ម.ម	- - Other, for roll film of a width less than 35 mm	u	35	10	10	0	
	9006.53.00	- - ផ្សេងទៀត សំរាប់ហ្វីលជារ៉ូឡូ ដែលមានទទឹង ៣៥ ម.ម	- - Other, for roll film of a width of 35 mm	u	35	10	10	0	
	9006.59	- - ផ្សេងទៀត :	- - Other :						
	9006.59.10	- - ឧបករណ៍ឡេស៊ែរថតឡាស៊ែរ ឬកំណត់រូបភាពជាមួយនឹងប្រូសេស៊័ររូបភាព	- - - Laser photo plotters or imagesetters with raster image processor	u	35	10	10	0	
	9006.59.90	- - - ផ្សេងទៀត	- - - Other	u	35	10	10	0	
		- បរិធានបញ្ចាំងថតរូប និងអំពូលបរិធានបញ្ចាំងថតរូប :	- Photographic flashlight apparatus and flashbulbs :						
	9006.61.00	- - បរិធានបញ្ចាំងមានអំពូលអាចបញ្ចូលភ្លើងបាន	- - Discharge lamp ("electronic") flashlight apparatus	u	35	0	10	0	
	9006.69.00	- - ផ្សេងទៀត	- - Other	u	35	0	10	0	
		- ភាគ និងគ្រឿងបន្ទាប់បន្សំ :	- Parts and accessories:						
	9006.91	- - សំរាប់កាមេរ៉ា :	- - For cameras :						
	9006.91.10	- - - សំរាប់កាមេរ៉ានៃទីតាំងរងលេខ ៩០០៦.១០.០០ និង ៩០០៦.៣០.១០	- - - For cameras of subheading No. 9006.10.00 and 9006.30.10	kg	35	0	10	0	
	9006.91.30	- - - ផ្សេងទៀត សំរាប់កាមេរ៉ានៃទីតាំងរងលេខ ៩០០៦.៤០ ដល់ ៩០០៦.៥៣	- - - Other, for cameras of subheadings 9006.40 to 9006.53	kg	35	0	10	0	

	9006.91.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
	9006.99	- - ផ្សេងទៀត :	- - Other :						
	9006.99.10	- - - សំរាប់បរិធានបង្កើតពន្លឺកំងសំរាប់ថតរូប	- - - For photographic flashlight apparatus	kg	35	0	10	0	
	9006.99.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
90.07		ម៉ាស៊ីនថតភាពយន្ត និងម៉ាស៊ីនបញ្ចាំងភាពយន្តទោះជាមានភ្ជាប់ ឬមិនភ្ជាប់នូវបរិធានសំរាប់ថតឬបញ្ចេញសំលេងក៏ដោយ ។	**Cinematographic cameras and projectors, whether or not incorporating sound recording or reproducing apparatus.**						
		- កាមេរ៉ា ម៉ាស៊ីនថត:	- Cameras :						
	9007.11.00	- - សំរាប់ហ្វីលដែលមានទទឹងតូចជាង ១៦ ម.ម ឬសំរាប់ហ្វីល ៨ ម.ម ឌុប	- - For film of less than 16 mm width or for double-8 mm film	u	15	0	10	0	
	9007.19.00	- - ផ្សេងទៀត	- - Other :	u	15	0	10	0	
	9007.20	- ម៉ាស៊ីនបញ្ចាំងរូប :	- Projectors :						
	9007.20.10	- - សំរាប់ភាពយន្តដែលមានទទឹងតូចជាង ១៦ មម	- - For film of less than 16 mm in width	u	15	0	10	0	
	9007.20.90	- - ផ្សេងទៀត	- - Other	u	15	0	10	0	
		- ភាគ បំណែក និងគ្រឿងបន្លាស់បន្សំ	- Parts and accessories:						
	9007.91.00	- - សំរាប់កាមេរ៉ា ម៉ាស៊ីនថត	- - For cameras	kg	15	0	10	0	
	9007.92.00	- - សំរាប់ម៉ាស៊ីនបញ្ចាំងរូប	- - For projectors	kg	15	0	10	0	
90.08		ម៉ាស៊ីនបញ្ចាំងរូបភាព បរិធានពង្រីក ឬបង្រួមរូបថត(ក្រៅពីម៉ាស៊ីនថតភាពយន្ត)	**Image projectors, other than cinematographic; photographic (other than cinematographic) enlargers and reducers.**						
	9008.10.00	- ស្លាយម៉ាស៊ីនបញ្ចាំងរូប	- Slide projectors	u	15	0	10	0	
	9008.20.00	- មីក្រូហ្វីល និងប្រដាប់អានមីក្រូហ្វីម ឬមីក្រូហ្វីសផ្សេងទៀតទោះអាច ឬពុំអាចផលិតថតចម្លង	- Microfilm, microfiche or other microform readers, whether or not capable of producing copies	u	15	0	10	0	
	9008.30.00	- ម៉ាស៊ីនបញ្ចាំងរូបផ្សេងទៀត	- Other image projectors	u	15	0	10	0	

	9008.40	- ប្រដាប់ពង្រីក និងបង្រួមរូបថត (ក្រៅពីសំរាប់ភាពយន្ត) :	- Photographic (Other than cinematographic) enlargers and reducers :						
	9008.40.10	- - ឧបករណ៍ឯកទេសខាងឧស្សាហកម្មបោះពុម្ព ។	- - Specialised equipment for use in the printing industry	u	15	0	10	0	
	9008.40.90	- - ផ្សេងទៀត	- - Other	u	15	0	10	0	
	9008.90	- ភាគ បំណែក និងគ្រឿងបន្លាស់បន្សំ :	- Parts and accessories :						
	9008.90.10	- - នៃទំនិញនៃទីតាំងរង ៩០០៨.២០	- - Of the goods of subheading 9008.20	kg	15	0	10	0	
	9008.90.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
90.10		បរិធាន និងសំភារៈសំរាប់ឡាបូលាង ថតរូបថត ឬភាពយន្តរួមបញ្ចូលទាំងបរិធានសំរាប់បញ្ចាំង ឬគូរគំនូរបរិបថលើវត្ថុធាតុសីមីកុងឌុចទ័រដោយប្រែប្រួលនៅកន្លែងផ្សេងទៀតនៃជំពូកនេះ ។ ឧបករណ៍ឆ្លុះដោយការស្ទើ ណេកាតូស្កុប ផ្ទាំងសំពត់សំរាប់ទទួលរូបបញ្ចាំង ។	**Apparatus and equipment for photographic (including cinematographic) laboratories (including apparatus for the projection or drawing of circuit patterns on sensitised semiconductor materials), not specified or included elsewhere in this chapter, negatoscopes; projection screens.**						
	9010.10.00	- បរិធាន និងហ៊ីត្វាសំរាប់លាងដោយស្វ័យប្រវត្តិនូវហ្វីលថតរូប ហ្វីលថតភាពយន្ត ឬផ្តិតរូបលើក្រដាសផ្តិតរូបជារុំ ឬសំរាប់បោះពុម្ពដោយស្វ័យប្រវត្តិហ្វីលលាងហើយលើក្រដាសផ្តិតរូបជារុំ ។	- Apparatus and equipment for automatically developing photographic(including cinematographic) film or paper in rolls or for automatically exposing developed film to rolls of photographic paper	u	15	0	10	0	
	9010.50	- បរិធាន និងឧបករណ៍ផ្សេងទៀតសំរាប់ទីពិសោធន៍ថតរូប (រាប់បញ្ចូលទាំងសំរាប់ភាពយន្ត) ណេហ្គាតូស្កុប ។	- Other apparatus and equipment for photographic (including cinematographic) laboratories; negatoscopes						
	9010.50.10	- - បរិធានសំរាប់គំរោងឬគំនូរនៃសៀគ្វីលើស៊ុបគ្រេតវែមដ៏សំរាប់ផលិតកម្ម នៃ PCB/PWBs	- - Apparatus for the projection or drawing of circuit patterns on sensitized substrates for the manufacture of PCB/PWBs	u	15	0	10	0	
	9010.50.90	- - ផ្សេងទៀត	- - Other	u	15	0	10	0	
	9010.60.00	- ផ្ទាំងសំពត់សំរាប់បញ្ចាំង	- Projection screens	u	15	0	10	0	
	9010.90	- ភាគ និងគ្រឿងបន្លាស់បន្សំ :	- Parts and accessories :						

	9010.90.10	- - សំរាប់ផ្ទាំងសំរាប់បញ្ចាំង ឬសំរាប់វត្ថុនៃអនុក្បាលលេខ ៩០១០.១០.០០	- - For projection screens, or for articles of subheading No 9010.10.00	kg	15	0	10	0	
	9010.90.30	- - ភាគ បំណែក និងគ្រឿងបន្លាស់ នៃបរិធានសំរាប់បញ្ចាំង ឬគូរសៀគ្វីសំរាប់សែនស៊ីទាយស៊ីបស្ត្រេតសំរាប់ផលិតកម្មផ្ទាំងសៀគ្វី ។	- - Parts and accessories of the apparatus for the projection or drawing of circuit patterns on sensitized substrates for the manufacture of PCB/PWBs	kg	15	0	10	0	
	9010.90.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
90.11		សមាសធាតុអតិសុខុមទស្សន៍អុបទិក រាប់ទាំងអតិសុខុមរូប និងការថតភាពយន្តអតិសុខុមទស្សន៍ ឬបញ្ចាំងវត្ថុល្អិតៗ។	**Compound optical microscopes, including those for microphotography, cinephotomicrography or microprojection.**						
	9011.10.00	- អតិសុខុមទស្សន៍ស្តេរ៉េអូស្កូប	- Stereoscopic microscopes	u	7	0	10	0	
	9011.20.00	- អតិសុខុមទស្សន៍ផ្សេងទៀតសំរាប់ការថតរូបអតិសុខុមទស្សន៍ ការថតភាពយន្តអតិសុខុមទស្សន៍ និងការបញ្ចាំងវត្ថុល្អិតៗ	- Other microscopes, for photomicrography, nephotomicrography or microprojection	u	7	0	10	0	
	9011.80.00	- អតិសុខុមទស្សន៍ផ្សេងទៀត	- Other microscopes	u	7	0	10	0	
	9011.90.00	- ភាគ បំណែក និងគ្រឿងបន្លាស់	- Parts and accessories	kg	7	0	10	0	
90.12		អតិសុខុមទស្សន៍ក្រៅពីអតិសុខុមទស្សន៍អុបទិក និងបរិធានផ្លាតពន្លឺ	**Microscopes other than optical microscopes and diffraction apparatus**						
	9012.10.00	- អតិសុខុមទស្សន៍ក្រៅពីអតិសុខុមទស្សន៍អុបទិក និងបរិធានផ្លាតពន្លឺ	- Microscopes other than optical microscopes and diffraction apparatus	u	7	0	10	0	
	9012.90.00	- ភាគ បំណែក និងគ្រឿងបន្លាស់	- Parts and accessories	kg	7	0	10	0	
90.13		បរិធានប្រើគ្រីសតាល់រាវដែលមិនមែនជាគ្រឿងដែលចែងក្រោមលេខក្បាលផ្សេង ស៊េឡាហ្សែរក្រៅពីឌីយ៉ូតឡាហ្សែរ បរិធាន និងឧបករណ៍អុបទិកផ្សេងទៀតគ្មានឈ្មោះ និងមិនបានរៀបរាប់ក្នុងជំពូកនេះ ។	**Liquid crystal devices, not constituting articles provided for more specifically in other heading, lasers, other than laser diodes; other optical appliances and instruments, not specified or included elsewhere in this chapter.**						
	9013.10.00	- កែវយឹតភ្ជាប់ទៅនឹងអាវុធ ពើរីស្កូប កែវយឹតសំរាប់ភាគនៃម៉ាស៊ីន បរិធាន ឧបករណ៍ នៃជំពូកនេះ ឬផ្នែក XVI ។	- Telescopic sights for fitting to arms; periscopes; telescopes designed to form parts of machines, appliances instruments or apparatus of this Chapter or Sections XVI	u	35	0	10	0	
	9013.20.00	- ឡាហ្សែរ ក្រៅពីឌីយ៉ូតឡាហ្សែរ	- Lasers, Other than laser diodes	u	35	0	10	0	

	9013.80	- ប្រដាប់ប្រដារ បរិធាន និងឧបករណ៍ផ្សេងទៀត :	- Other devices, appliances and instruments :						
	9013.80.10	- - ឧបករណ៍ផ្ទៀងផ្ទាត់កំហុសអុបទិក និងឧបករណ៍ជួសជុលសំរាប់ PCB/PWBs និង PCAs	- - Optical error verification and repair apparatus for PCB/PWBs and PCAs	u	35	0	10	0	
	9013.80.20	- - ឧបករណ៍ប្រើគ្រីស្តាល់រាវ	- - Liquid crystal devices	u	35	0	10	0	
	9013.80.90	- - ផ្សេងទៀត	- - Other	u	35	0	10	0	
	9013.90	- ភាគ បំណែក និងគ្រឿងបន្លាស់បន្សំ :	- Parts and accessories :						
	9013.90.10	- - ភាគ បំណែក និងគ្រឿងបន្លាស់បន្សំនៃទំនិញទីតាំងរងលេខ ៩០១៣.២០.00 (ITA/2 (AS2))	- - Parts and accessories of goods of subheading 9013.20.00 [ITA/2 (AS2)]	kg	35	0	10	0	
